# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបក្រុម **JICA** ជប៉ុន



នៅរសៀលថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានជួបជាមួយក្រុមទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន **JICA** ដឹកនាំដោយលោកស្រី **Rieko TAMURA** នាយកគ្រប់គ្រងប្រភពធន់ធានទឹក ក្រុមទី១ នៃនាយកដ្ឋានបរិស្ថានសកល នៃអង្គការ JICA ជប៉ុន ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ទាក់ទងនិងការធ្វើរបាយការណ៍សង្ខេប ស្តីពីគម្រោងកសាងសមត្ថភាពអង្គភាពរដ្ឋាករទឹកសាធារណៈ នៅកម្ពុជា ជំហ៊ានទី៣ និងការត្រួតពិនិត្យ វាយតម្លៃពាក់កណ្តាលអណត្តិនៃគម្រោង ។

លោកស្រីនាយក **Rieko TAMURA** បានធ្វើរាយការណ៍សង្ខេប ដោយបានបញ្ជាក់ថា៖គម្រោងអង្គការ JICA បានចាប់ផ្តើមដំណើរការនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ បានធ្វើឱ្យមាននូវវឌ្ឍនភាពដ៏ជាក់លាក់មួយ ឆ្ពោះទៅរកការសម្រេចឱ្យបាននូវគោលបំណងចម្បងនៃការកសាងសមត្ថភាពដល់បណ្តាអង្គភាពរដ្ឋាករទឹកទាំង០៨ ខេត្ត គោលដៅ រួមមាន៖ខេត្ត សៀមរាប-បាត់ដំបង-ព្រះសីហនុ-កំពត-កំពង់ចាម-កំពង់ធំ-ពោធិ៍សាត់ និងស្វាយរៀង ។



លទ្ធផលគួរកត់សំគាល់មួយចំនួន ត្រូវបានគេសង្កេតឃើញមានសម្រេចបានការអនុវត្តគម្រោង ក្នុងរយៈពេលពាក់កណ្តាលអណត្តិដំបូង ជាពិសេសការធ្វើឱ្យទិន្នន័យហិរញ្ញវត្ថុរបស់បណ្តាអង្គភាពរដ្ឋាករទឹកសាធារណៈ ក្នុងខេត្តគោលដៅមានភាពគួរឱ្យជឿជាក់បាន ។ ចំពោះលទ្ធផលដែលរំពឹងទុកសំខាន់ៗរួមមានៈ –ទិន្នន័យហិរញ្ញវត្ថុរបស់អង្គភាពរដ្ឋាករទឹកសាធារណៈក្នុងខេត្តគោលដៅ កាន់តែគួរជឿជាក់ជាងមុន–បច្ចុប្បន្នអង្គភាបចំនួន០៧ ក្នុងខេត្តគោលដៅទាំង៨ ទទួលបាននូវប្រាក់ចំណេញសុទ្ធ សម្រាប់មួយឆ្នាំ ពីអាជីវកម្មរបស់ពួកគេ–ការធ្វើផែនការហិរញ្ញវត្ថុ ដោយផ្អែកលើទឡ្ហីករណ៍ (ភស្តុតាង)នឹងអាចធ្វើទៅបាន–ច្បាប់ផ្គត់ផ្គង់ទឹកស្អាតនឹងត្រូវបានគេព្រាងឡើង ។

ចំពោះកត្តាជោគជ័យ គឺៈ–ការផ្តោតការយកចិត្តទុកដាក់ និងការរៀបចំលំដាប់លំដោយ នៃសកម្មភាពនានា ដោយមានភាពសមស្រប–ដំណើរទស្សនៈកិច្ចតាមខេត្ត/ភាពជាអ្នកដឹកនាំនៃការគ្រប់គ្រងគម្រោង–សមត្ថភាពរបស់អង្គភាព រដ្ឋាករទឹកសាធារណៈក្នុងខេត្តគោលដៅ–ឥទ្ធិពលប៉ះពាល់ផ្នែកហិរញ្ញវត្ថុរបស់ជំនួយកំពុងដំណើរការផ្សេងទៀត ដូចជាៈ គម្រោងជំនួយឥតសំណងរបស់ប្រទេសជប៉ុន សម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត សម្រាប់ខេត្តពោធិ៍សាត់ ព្រះសីហនុ បាត់ដំបង និងកំពង់ចាម ។

ចំពោះឧបសគ្គ និងបញ្ហាប្រឈមនានា រួមមានៈការពន្យាពេលក្នុងការអនុវត្តគម្រោង ដោយសារការបោះឆ្នោតសភាជាតិ នៅឆ្នាំ២០១៣–កំណែទម្រង់ក្រសួងរបស់រាជរដ្ឋាភិបាល និងការបង្កើតនូវក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលធ្វើឱ្យមានការផ្លាស់ប្តូរមន្ត្រី–កង្វះនូវការយល់ឃើញដូចគ្នា អំពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា–ភាពខុសគ្នានៃសមត្ថភាព ភាពម្ចាស់ការ និងការយកចិត្តទុកដាក់ របស់អង្គភាពរដ្ឋាករទឹកសាធារណៈ ក្នុងខេត្តគោលដៅទាំង០៨ ។

ដោយឡែកចំពោះសមិទ្ធិផលរបស់គម្រោង រួមមានៈ–ការរៀបចំសម្រាប់ផែនការអាជីវកម្ម–ការត្រួតពិនិត្យផែនការអាជីវកម្ម–ការកសាងសមត្ថភាពសម្រាប់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីវាយតម្លៃស្នាដៃរបស់អង្គភាពរដ្ឋាករ

ទឹកសាធារណៈ ក្នុងខេត្តកោលដៅ–ការអភិវឌ្ឍន៍និងគ្រប់គ្រងធនធានមនុស្សឱ្យបានប្រសើរឡើង នៅតាមបណ្ដាអង្គភាពរដ្ឋាករទឹកសាធារណៈ ក្នុងខេត្តកោលដៅ ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណ ចំពោះទីភ្នាក់ងារ JICA ជប៉ុន ដែលបានដើរតួយ៉ាងសំខាន់ក្នុងសកម្មភាពអភិវឌ្ឍន៍នៅកម្ពុជា ជាពិសេជំនួយលើវិស័យទឹកស្អាត ។ ជំនួយរបស់ប្រទេសជប៉ុន តាមរយៈអង្គការ JICA លើវិស័យទឹកស្អាត ចាត់ទុកថាជាគំរូ ហើយកម្ពុជាទទួលបានជោគជ័យគួរជាទីមោទនៈលើវិស័យនេះ ជាពិសេសអង្គភាពរដ្ឋាករទឹកភ្នំពេញទទួលបានពានរង្វាន់ ជាបន្តបន្ទាប់ពីស្ថាប័នវាយតម្លៃអន្តរជាតិនានា ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងពីការខិតខំយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សលើវិស័យទឹកស្អាតសម្រាប់ទាំងអស់គ្នា ។ ដូច្នេះគំម្រោងជំនួយរបស់ជប៉ុន ដើម្បីកសាងសមត្ថភាពអង្គភាពរដ្ឋាកតទឹកសាធារណៈនៅកម្ពុជា ពិតជាមានសារៈសំខាន់ ដែលត្រូវការសហការសម្រេចឱ្យបានជោគជ័យ ដែលគម្រោងនេះ នឹងបញ្ចប់នៅចុងឆ្នាំ២០១៧ ។ ឯកឧត្តមបានបន្តថា: កត្តាសំខាន់ ដើម្បីសម្រេចជោគជ័យនៃគម្រោង ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានផ្ដល់សារៈសំខាន់លើប្រព័ន្ធគ្រប់គ្រង និងការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាព ស្ថាប័ន និងមន្ត្រី ក្នុងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងអង្គភាពរដ្ឋាករទឹកសាធារណៈ ហើយឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ នឹងកោះប្រជុំរៀងរាល់២ខែដងរវាង Jica និងរដ្ឋាករទឹកសាធារណៈ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានស្នើឱ្យដៃគូជប៉ុនសហការធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីទឹកស្អាត នៅកម្ពុជាឱ្យបានកាន់តែឆាប់ ពីព្រោះច្បាប់នេះជាឧបករណ៍គតិយុត្តដ៏សំខាន់សម្រាប់ប្រតិបត្តិការវិស័យទឹកស្អាតប្រកប ដោយប្រសិទ្ធិភាព និងតម្លាភាព ។